# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១០ អនក្រ.បក

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០១

# អនុក្រឹត្យ

## ស្តីពីការតំឡើងឋានៈមជ្ឈមណ្ឌលបច្ចេកទេស និងវិជ្ជាជីវៈព្រះកុសុមៈ ទៅជាវិទ្យាស្ថានពហុបច្ចេកទេស ព្រះកុសុមៈ របស់ក្រសួងអប់រំ យុវជន និង កីឡា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និង គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស

-បានឃើញសេចក្តីសំរេចលេខ ៨១ សរច ចុះថ្ងៃទី ២១/៧/១៩៨១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតិអោយក្រសួងអប់រំ បង្កើត មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

-តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា

## <u>សំរេច</u>

<u>មាត្រា១</u>: ប្រែក្លាយ និងតំឡើងឋានៈមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈព្រះកុសុមៈ ទៅជាវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ Preah Kossomak Polytechnic Institute "វ.ព.ប.ព.ក." ។ វិទ្យាស្ថាននេះត្រូវស្ថិតនៅក្រោមឱវាទ ក្រសួងអប់រំ យុវជន និង កីឡា ។

<u>មាត្រា២</u>: វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈមានភារកិច្ច :

-អប់រំបណ្តុះបណ្តាលធនធានមនុស្សតាំងពីកំរិតបណ្តុះបណ្តាលវិជ្ជាជីវៈ មធ្យមសិក្សាបច្ចេកទេស និងវិស្វករ

ដើម្បីឆ្លើយតប ទៅនឹងតម្រូវការរីកចំរើននៃសេដ្ឋកិច្ចទីផ្សារសេរី និង គោលនយោបាយអាទិភាព សំរាប់ការអភិវឌ្ឍន៍ ប្រទេសជាតិរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣:** វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ មានឋានៈស្មើថ្នាក់នាយកដ្ឋាន ។

**មាត្រា៤:** នាយក វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ មានបុព្វសិទ្ធិស្មើនឹងប្រធាននាយកដ្ឋាន និងមាននាយករងមួយរូប ឬច្រើនរូប ជាជំនួយការចាំបាច់ ។

**មាត្រា៥:** ចំពោះមុខនេះ វិទ្យាស្ថាន ពហុបច្ចេកទេសព្រះកុសុមៈ មានៈ

-ការិយាល័យរដ្ឋបាល និង ហិរញ្ញកិច្ច

-ការិយាល័យផែនការ និង អភិវឌ្ឍន៍

-ការិយាល័យ ទំនាក់ទំនងឧស្សាហកម្ម

-ការិយាល័យ អប់រំ

-ដេប៉ាតឺម៉ង់ សំណង់ស៊ីវិល

-ដេប៉ាតឺម៉ង់ អេឡិចត្រូនិច

-ដេប៉ាតឺម៉ង់ អគ្គិសនី

ទៅអនាគតវិទ្យាស្ថាន នឹងអាចបើកការិយាល័យ និងដេប៉ាតឺម៉ង់មួយចំនួនទៀតតាមសំណូមពរភារកិច្ចជាក់ស្តែង។

**មាត្រា៦:** វិទ្យាស្ថាន ពហុបច្ចេកទេសព្រះកុសុមៈ កាន់កាប់ និងប្រើប្រាស់ គណនេយ្យតាមប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវបានឧបត្ថម្ភពីថវិកាជាតិ សំរាប់បណ្តុះបណ្តាល និងមានខ្ទង់គណនេយ្យដោយឡែក ។

**មាត្រា៧:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៨" ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ